**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអភិបូជាចំហានទីពីរនៅភ្នំពេញថ្មី**
**ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៨**
*អាវុធដើម្បីភ្ជាប់ជាមួយព្រះយេស៊ូ*

អត្ថបទទី១៖ កណ ៩,៨-១៥
អត្ថបទទី២៖ ១សល ១,១៨-២២
ដំណឹងល្អ៖ មក ១,១២-១៥

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះព្រះយេស៊ូបានទៅវាលរហោស្ថាន ដែលជាកន្លែងមួយដែលគ្មានដើមឈើ គ្មានសត្វរស់នៅ ជាកន្លែងដែលគ្មានមនុស្សរស់នៅ។ **តើព្រះយេស៊ូទៅធ្វើអ្វីនៅវាលរហោស្ថាន?** ពេលយើងស្តាប់នៅក្នុងគម្ពីរដំណឹងល្អ "**ព្រះអង្គគង់នៅវាលរហោស្ថាន ត្រូវមាសារតាំងល្បួងអស់រយៈពេល៤០ថ្ងៃ**" ព្រះអង្គទទួលការល្បួងអស់៤០ថ្ងៃដោយសារមាសារតាំងសាកល្បងមើលទឹកចិត្តព្រះយេស៊ូ តើព្រះអង្គជាប់ជាមួយព្រះជាម្ចាស់ពិតមែនឬអត់? តើព្រះយេស៊ូមានព្រះហឫទ័តតែមួយជាមួយព្រះជាម្ចាស់ពិតមែនឬអត់?

វាលរហោស្ថាន ណែនាំឲ្យយើងនឹកឃើញដល់ជីវិតរបស់យើងទាំងអស់ ដោយសារគ្មានអ្វីដែលណែនាំឲ្យយើងសប្បាយ គ្មានអ្វីដែលណែនាំឲ្យយើងវង្វេងអារម្មណ៍ យើងត្រូវតែមូលអារម្មណ៍ដើម្បីនឹកដល់ជីវិតរបស់យើងដូចម្តេច? ជីវិតរបស់យើងណែនាំឲ្យយើងធ្វើអ្វីខ្លះ? វាលរហោស្ថាន ជាកន្លែមួយដែលស្ងៀមស្ងាត់ដែលងាចឲ្យយើងមើលឃើញជីវិតរបស់យើង ជាពិសេសយើងអាចបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់បាន។

អ្វីដែលសំខាន់បំផុតសម្រាប់យើងដែលកំពុងដើរតាមព្រះយេស៊ូ គឺបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់។ ហេតុនេះហើយរដូវ៤០ថ្ងៃនេះ ជាពេលវេលាមួយឲ្យយើងចូលនៅក្នុងវាលរហោស្ថាននៃជីវិតរបស់យើង **ទីមួយ** សាកល្បងមើលចិត្តរបស់យើងតើយើងស្រឡាញ់ព្រះជាម្ចាស់ដល់កម្រិតណា **ទីពីរ** ដើម្បីបង្កើតទំនាក់ទំនងរវាងយើងនឹងព្រះជាម្ចាស់។ នៅក្នុង៤០ថ្ងៃ យើងមានពេលដើម្បីឲ្យជីវិតរបស់យើងជាជីវិតថ្មី នៅពេលព្រះយេស៊ូទទួលការល្បួងហើយ ព្រះអង្គមានព្រះបន្ទូលដំបូងថា "**ព្រះជាម្ចាស់ក៏ហៀបនឹងគ្រងរាជ្យដែរ ចូរនាំគ្នាប្រែចិត្តគំនិតហើយជឿលើដំណឹងល្អចុះ**"។ ៤០ថ្ងៃដើម្បីកែប្រែចិត្តគំនិត ៤០ថ្ងៃដើម្បីជឿលើដំណឹងល្អថែមទៀត ៤០ថ្ងៃនដើម្បីឲ្យយើងសាកល្បងមើលទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់ សេចក្តីស្រឡាញ់ដែលយើងមានចំពោះព្រះជាម្ចាស់។ តាម

ពិតនៅក្នុង៤០ថ្ងៃ ព្រះយេស៊ូបានចូលនៅក្នុងការប្រយុទ្ធជាមួយមាសារតាំង ការប្រយុទ្ធទាមទារឲ្យមានអាវុធ។ សម្រាប់បងប្អូនដែលសុំឲ្យព្រះសហគមន៍ត្រាស់ហៅយ៉ាងឱឡារិកពេលវេលា៤០ថ្ងៃខាងមុននេះប្រហែលយើងចង់ប្រឆាំងជាមួយព្រះជាម្ចាស់ យើងចង់ប្រឆាំងជាមួយព្រះសហគមន៍ ដោយសារយើងចង់សាកល្បងមើលចិត្តរបស់យើងស្រឡាញ់ព្រះជាម្ចាស់ដល់កម្រិតណា? ដោយសារបើទទួលអគ្គសញ្ញាជ្រមុជទឹកហើយយើងជាប់ជាមួយព្រះជាម្ចាស់អស់មួយជីវិត។

ដូច្នេះនៅក្នុង៤០ថ្ងៃ ដើម្បីចូលនៅក្នុងការតយុទ្ធរបស់ព្រះយេស៊ូ យើងមានអាវុធដើម្បីចូលនៅក្នុងការល្បួងជាមួយមាសារតាំង ដើម្បីសាកល្បងមើលជីវិតរបស់យើង ដើម្បីសាកល្បងមើលតើយើងស្រឡាញ់ព្រះជាម្ចាស់ឬអត់?

**អាវុធទីមួយ** គឺ **ព្រះវិញ្ញាណដ៏វិសុទ្ធ** ដែលព្រះយេស៊ូបានទទួលនៅពេលទទួលពិធីជ្រមុជទឹក ព្រះវិញ្ញាណដ៏វិសុទ្ធជាពន្លឺរបស់ព្រះជាម្ចាស់។ ព្រះវិញ្ញាណដ៏វិសុទ្ធជាដង្ហើមរបស់ព្រះជាម្ចាស់ដែលណែនាំឲ្យយើងពោរពេញដោយជីវិត ណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតដ៏អស្ចារ្យ ប្លែកពីគេយើងមិនរស់នៅដោយសារមានវិញ្ញាណដទៃ យើងរស់នៅដោយសារវិញ្ញាណរបស់ព្រះជាម្ចាស់។ គ្រីស្តបរិស័ទជាមនុស្សប្លែក ដោយសារយើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ វិញ្ញាណរបស់យើងជាប់ជាមួយវិញ្ញាណរបស់ព្រះជាម្ចាស់។ ពេលចេញពីព្រះវិហារវិញ ពេលយើងទៅផ្ទះប្រហែលមានគេសួរ **ហេតុអ្វីគូសឈើឆ្កាងលើថ្ងាសដូចនេះ?** ពិតមែនយើងប្លែក ដោយសារព្រះវិញ្ញាណណែនាំឲ្យយើងមានកម្លាំង ព្រះវិញ្ញាណដែលណែនាំយើងទៅជាមនុស្សពេញលក្ខណៈ ព្រះវិញ្ញាណដែលណែនាំឲ្យយើងពោរពេញដោយសេចក្តីស្រឡាញ់ គឺវិញ្ញាណរបស់ព្រះជាម្ចាស់។

ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធកំពុងធ្វើដំណើរគង់នៅជាមួយយើង ដូចធ្វើដំណើរជាមួយព្រះយេស៊ូដើម្បីឲ្យជីវិតរបស់យើងទទួលពន្លឺមួយយ៉ាងច្បាស់លាស់ ដើម្បីឲ្យយើងដើរតាមផ្លូវរបស់ព្រះយេស៊ូតែម្តង។ ផ្លូវរបស់ព្រះយេស៊ូគឺ "**ត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូបានស្រឡាញ់យើងដែរ**" វិញ្ញាណណែនាំឲ្យយើងចេះស្រឡាញ់គ្នាដូចព្រះយេស៊ូស្រឡាញ់យើងដែរ។

**អាវុធទីពីរ គឺ ការអធិដ្ឋាន** នៅក្នុងរដូវ៤០ថ្ងៃនេះ ឲ្យយើងយកពេលដើម្បីអធិដ្ឋាន កុំឲ្យយើងធ្វើយូរៗម្ដងពេលមានសំណាក់ធម៌។ នៅពេលយើងអធិដ្ឋានជាមួយ ផ្គាំនៃធម៌មេត្តាករុណានៅពេលនោះ ខ្ញុំជឿថាយើងបានភ្ជាប់ជាមួយព្រះយេស៊ូខ្លាំងណាស់ នៅពេលយើងប្រកាសថា "**ឱព្រះយេស៊ូអើយ! ទូលបង្គំទុកចិត្តលើព្រះអង្គយ៉ាងខ្លាំងណាស់ ឱព្រះយេស៊ូអើយ! ទូលបង្គំសូមផ្ញើជីវិតរបស់ទូលបង្គំលើព្រះអង្គពិតមែន ឱព្រះយេស៊ូអើយ! ទូលបង្គំស្រឡាញ់ព្រះអង្គយ៉ាងខ្លាំងមែនទែន**"។ ជីវិតរបស់យើងជាគ្រីស្ដបរិស័ទភ្ជាប់ជាមួយព្រះយេស៊ូ នៅពេលយើងអធិដ្ឋាន ពេលយើងស្ងៀមស្ងាត់ ដើម្បីបង្កើតទំនាក់ទំនងជាមួយព្រះយេស៊ូយ៉ាងពិតប្រាកដ។ យើងដឹងថា អ្នកដែលអធិដ្ឋានព្រះបិតាដែលនៅស្ថានបរមសុខស្ដាប់ពាក្យទូលអង្វររបស់យើងនិងឆ្លើយតប។

ថ្ងៃទី១៨ ខែកុម្ភៈ ជាថ្ងៃពិសេសមួយសម្រាប់ព្រះសហគមន៍កាតូលិក ព្រោះថាកាលពី១៦០ឆ្នាំមុន មានកូនស្រីម្នាក់ដែលមានអាយុ១៤ឆ្នាំដែលឈ្មោះប៊ែរណាដែត ពានឃើញព្រះនាងម៉ារី ១៥ដងផ្ទាល់ភ្នែក នៅទីក្រុងលួតប្រទេសបារាំង។ ពេលនោះគាត់បានដើរជាមួយមិត្តភក្ដរបស់គាត់មកពីសាលាវិញ ដូចជាមានអ្វីទាក់ទាញគាត់ឲ្យចូលនៅក្នុងរូងភ្នំគាត់បានចូលហើយអធិដ្ឋានផ្គាំ គាត់បានឃើញយុវនារីម្នាក់ដែលសស្អាតណាស់ គាត់មិនដឹងថាជានរណា មានតែគាត់ដែលមើលឃើញមិត្តភក្ដរបស់គាត់ពីរនាក់ទៀតមើលមិនឃើញទេ។ ថ្ងៃទីពីរ ថ្ងៃទីបី គាត់បានទៅកន្លែងនោះហើយក៏បានឃើញទៀត ហើយស្ត្រីម្នាក់នោះបាននិយាយមកកាន់នាងថា "**ខ្ញុំនឹងបង្ហាញខ្លួនឲ្យនាងឃើញ១៥ដង**" ហើយពិតមែនគាត់បានឃើញ១៥ដងមែន។ នៅលើកទី១២ ស្ត្រីម្នាក់នោះបានប្រាប់នាងឲ្យទៅកាយដីនៅក្បែរនោះនឹងមានទឹកចេញ នៅថ្ងៃចុងក្រោយ ប៊ែរណាដែត បានសួរទៅស្ត្រីដែលបង្ហាញខ្លួននោះថា "**តើអ្នកឈ្មោះអ្វី?**" ស្ត្រីនោះឆ្លើយថា "**ខ្ញុំជាអ្នកដែលគ្មានជំពាក់បាប**" ប៊ែរណាដែតមិនយល់គ្មានជំពាក់បាបជាអ្វី ក៏បានទៅសួរលោកបូជាចារ្យម្នាក់គាត់ក៏ប្រាប់ថាមានតែព្រះនាងម៉ារីទេដែលគ្មានជំពាក់បាប ទើបដឹងថាជាព្រះនាងម៉ារី។ គាត់ពោរពេញដោយសេចក្ដីស្រឡាញ់ពីព្រះនាងម៉ារី ណែនាំឲ្យមនុស្សយើងទាំងអស់ទទួលពាក្យមួយយ៉ាងសំខាន់ពីព្រះនាងម៉ារីគឺ "**សុំកែប្រែចិត្តគំនិត ព្រោះយើងជាអ្នកមានបាប**" ចាប់ពីពេលនោះមក មានរាប់លាននាក់ជារៀងរាល់ឆ្នាំដែលបានធ្វើដំណើរទៅទីនោះ ដើម្បីគោរពព្រះនាងម៉ារី។ ប៉ុន្មានថ្ងៃមុន មានមនុស្សទី៧០ដែលបានទទួលការសង្គ្រោះពីព្រះនាងម៉ារីនៅ

កន្លែងនោះ តាមរយៈទឹកដែលព្រះនាងម៉ារីបានបង្ហាញឲ្យប៊ែរណាដែត។ មនុស្សទី៧០ នោះគឺជាបងស្រីម្នាក់ដែលគាត់ដើរមិនបានរយៈពេលយូរណាស់មកហើយ គាត់បានទៅអធិដ្ឋានផ្ដាំដូចគេដូចឯងនៅកន្លែងនោះ ក្រោយមកគាត់បានចូលនៅក្នុងអាងទឹកនោះ ពេលគាត់ទៅដល់អារាមរបស់គាត់វិញ គាត់បានបន្តអធិដ្ឋានផ្ដាំជាមួយក្រុមគាត់ពីរសប្ដាហ៍ក្រោយមក គាត់មានអារម្មណ៍ថាគាត់ក្ដៅនៅក្នុងខ្លួន ក្រោយមកគាត់អាចដើរបានធម្មតាវិញ។ នៅគ្រប់ទីកន្លែងមានភ្នំព្រះនាងម៉ារី ប៉ុន្តែយើងទទួលការសង្គ្រោះពីព្រះជាម្ចាស់លុះត្រាតែយើងអធិដ្ឋាន ជាអាវុធទីពីរដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់យ៉ាងពិតប្រាកដ។

**អាវុធទីបី គឺ ព្រះបន្ទូលរបស់ព្រះជាម្ចាស់** សូមជាប់ជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ខ្ញុំធ្លាប់សួរថា "**តើបងប្អូនស្រឡាញ់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាងគេគឺអ្វី?**" យើងសួរខ្លួនឯងថាតើមានព្រះបន្ទូលណាដែលណែនាំជីវិតខ្ញុំ ដើម្បីថ្ងៃនេះខ្ញុំសុំព្រះសហគមន៍ត្រាស់ហៅខ្ញុំយ៉ាងឱឡារិក និងទទួលអគ្គសញ្ញាជ្រមុជទឹកនៅពេលខាងមុខ។ នៅក្នុងរដូវ៤០ថ្ងៃនេះ ឲ្យយើងទាំងអស់គ្នាយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីចិញ្ចឹមជីវិតយើងថែមទៀត។ ឲ្យយើងស្ដាប់ព្រះបន្ទូល ដោយសារព្រះបន្ទូលជាព្រះយេស៊ូផ្ទាល់ ថ្ងៃនេះការសង្គ្រោះមានរូបរាងហើយ ដំណឹងល្អគឺព្រះយេស៊ូផ្ទាល់។ ពេលយើងស្ដាប់ព្រះបន្ទូល យើងដឹងថាជីវិតរបស់ខ្ញុំមានអត្ថន័យជ្រៅណាស់ ណែនាំឲ្យខ្ញុំដឹងថាខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីដឹកនាំជីវិតរបស់ខ្ញុំ។ អ្វីដែលសំខាន់បំផុត ឲ្យយើងភ្ជាប់ជាមួយព្រះយេស៊ូ ដោយត្រៀមខ្លួនដើម្បីជួបជាមួយព្រះអង្គផ្ទាល់។

**អាវុធទីបួន គឺ តមអាហារ និងចែករំលែក** នៅក្នុងរដូវ៤០ថ្ងៃ ជាពេលវេលាដើម្បីតមអាហារ ដើម្បីដឹងថាជីវិតរបស់យើងត្រូវការអ្វីខ្លះដើម្បីរស់នៅត្រឹមត្រូវ។ យើងត្រូវការនឹកឃើញ នៅជុំវិញយើងមានមនុស្សជាច្រើនដែលគ្មានសំណាងដូចយើងទេ នៅក្នុងព្រះសហគមន៍យើងរកឃើញគ្រួសារមួយយ៉ាងធំ ដែលធ្វើដំណើរជាមួយយើង លើកទឹកចិត្តយើង នៅជាមួយយើង ជាពិសេសណែនាំឲ្យយើងដើរតាមផ្លូវយ៉ាងពិសេស គឺទទួលជីវិតអស់កល្បជានិច្ច។ ដូច្នេះ យើងតមអាហារ ពេលយើងចែករំលែកជាមួយបងប្អូនឯទៀតៗ ពិតមែនយើងចូលនៅក្នុងរបៀបរបស់ព្រះយេស៊ូ ដែលបានធ្វើដំណើរពូភូមិមួយទៅភូមិមួយ ដើម្បីណែនាំឲ្យអ្នកជំងឺជាសះស្បើយ អ្នកស្រេកឃ្លានមានអាហារបរិបូរណ៍ អ្នកអស់សង្ឃឹមរកឃើញពន្លឺនៅក្នុងជីវិត។ យើងតមអាហារ និងចែករំលែក ដើម្បីផ្ដល់សក្ខីភាព

របស់ព្រះជាម្ចាស់ឲ្យមនុស្សលោកដឹងថា ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់។ នេះជាអ្វីដែលយើងចង់បង្ហាញដល់មនុស្សលោក តាមរបៀបដែលយើងរស់នៅ យើងជាមនុស្សអស្ចារ្យនៅក្នុងសម័យបច្ចុប្បន្ននេះ ដោយសារយើងបានទទួលបេសកកម្មមួយ គឺធ្វើយ៉ាងណាឲ្យបងប្អូនឯទៀតៗមើលឃើញតាមរយៈជីវិតរបស់យើងថា ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់។ ខ្ញុំសូមអញ្ជើញបងប្អូនដាក់ខ្លួនទីពឹងលើព្រះជាម្ចាស់ ដូចកូនទីពឹងលើឪពុកម្ដាយ ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺសម្រាប់មនុស្សដែលមានចិត្តដូចកូនក្មេង។ អាម៉ែន៕